


# ប្រតិទិនរបស់ប្រទេសជប៉ុន បានក្លាយជា 令和（れいわ）

នៅថ្ងៃទី០១ខែឧសភា ព្រះអង្គម្ចាស់ជប៉ុនបានឡើងគ្រងរាជជាអធិរាជថ្មី។ ចាប់ពីថ្ងៃនេះ យុគសម័យបង្ហាញពីឆ្នាំរបស់ប្រទេសជប៉ុនត្រូវបានផ្លាស់ប្តូរពី 平成（へいせい） ទៅជា 令和（れいわ）។

**យុគសម័យគឺជា**

រជ្ជកាលរបស់អធិរាជជប៉ុនត្រូវបានគេដាក់ឈ្មោះ។ នេះគេហៅថាយុគសម័យ។ យុគសម័យ កាលពីដើមត្រូវបានគេប្រើប្រាស់នៅក្នុងប្រទេសចិន។ យុគសម័យរបស់ជប៉ុនបានបន្តឥតឈប់ឈរអស់រយៈពេល១៣០០ឆ្នាំ ហើយ 令和（れいわ）គឺជាយុគសម័យទី២៤៨។ ប្រទេសដែលកំណត់យុគសម័យនៅក្នុងពិភពលោកបច្ចុប្បន្ននេះ មានតែប្រទេសជប៉ុនប៉ុណ្ណោះ។ សំរាប់ជនជាតិជប៉ុន យុគសម័យគឺជាវប្បធម៌មួយដែលភ្ជាប់អតីតកាល នឹងអនាគត។

នៅប្រទេសជប៉ុនប្រើទាំងគ្រឹស្តសករាជ និងយុគសម័យដើម្បីតំណាងឆ្នាំ។ នៅលើកឯកសារ ការសរសេរឆ្នាំ គេសរសេរជាអក្សរអង់គ្លេស ដូចជា 平成 (Heisei) 31 年 គេសរសេរជា「H31」។ ចំពោះ 令和 គឺReiwa ដូច្នេះឆ្នាំនេះ れいわ ឆ្នាំទី១គឺត្រូវសរសេរ「R1」។ ឆ្នាំដំបូងត្រូវបានគេចាត់ទុកជាឆ្នាំថ្មី「元年（がんねん）」ដូច្នេះ れいわ ឆ្នាំទី១ក៏មានគេចាត់ទុក れいわ ឆ្នាំថ្មីផងដែរ។

ឯកសារឬក៏វិញ្ញាបណ្ណបត្រជាដើមដែលត្រូវដាក់ទៅសាលាក្រុង រហូតមកដល់ឥឡូវនេះត្រូវបានប្រើឆ្នាំយុគសម័យ ប៉ុន្តែការប្រើឆ្នាំគ្រឹស្តសករាជក៏មានកាន់តែច្រើនឡើងផងដែរ។ ឯកសារដែលបានដាក់ស្នើសុំដោយជនបរទេសដូចជាសិក្ខាកាមជាដើមត្រូវសរសេរជាឆ្នាំគ្រឹស្តសករាជទើបល្អ។

**អត្ថន័យរបស់ れいわ?**

れいわ គឺជាពាក្យដែលត្រូវបានជ្រើសរើសពីការប្រមូលកំណាព្យជប៉ុនបុរាណដែលគេហៅថា まんようしゅう(manyoushuu) ដែលបានបង្កើតកាលពីជាង១២០០ឆ្នាំមុន។ ពាក្យ「令」មានន័យថា លំដាប់» ហើយក៏មានន័យថា«សំណាងល្អ»និង «ស្រស់ស្អាត»ផងដែរ។ ពាក្យ「和」មានន័យថា«ភាពសុខដុម» នឹងត្រូវបានគេប្រើនៅក្នុងអត្ថន័យ«សន្តិភាព»ផងដែរ។ ផ្គុំបញ្ចូលគ្នាមកមានន័យថា «ភាពសុខដុមដ៏ស្រស់ស្អាត» «ភាពសុខដុមដែលសំណាងល្អ»ជាដើម។ គេសង្ឃឹមថាពាក្យ 令和 និងក្លាយជាជំនាន់ដ៏អស្ចារ្យមួយ។



**ត្រូវប្រុងប្រយ័ត្នអំពីការនាំយផលិតផលសាច់និងបន្លែខុសច្បាប់ពីបរទេស ត្រូវបានកំណត់ការដាក់ពិន័យយ៉ាងធ្ងន់ធ្ងរ**

ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺដែលបានរីករាលដាលនៅទូទាំងពិភពលោកចូលទៅក្នុងប្រទេសជប៉ុន។ ចាប់ពីថ្ងៃទី២២ខែមេសា សាច់និង ផលិតផលសាច់ដូចជា (សាច់ក្រកក្តាមជាដើម)គឺមិនអាចនាំចូលប្រទេសជប៉ុនបានទេ។ប្រសិនបើឥវ៉ាន់ឬវត្ថុដែលត្រូវបានគេត្រួតពិនិតនៅប្រលានយន្តហោះ គ្មានលិខិតប្រកាសនាំចូល (ឬវិញ្ញាបនបត្រត្រួតពិនិត្យដែលចេញដោយរដ្ឋាភិបាលទេ) ។ គឺត្រូវដាក់ពន្ធធនាគារហូតដល់៣ឆ្នាំឬពិន័យជាប្រាក់រហូតដល់ ១លានយ៉េន ។ ហេតុដូចច្នេះហើយសូមកំយករបស់ដែលគេហាមឃាត់ចូលប្រទេសជប៉ុន ជាដាច់ខាត ។

## INFORMATION

**ការរៀនភាសាជប៉ុនជាក្រុម**
**ឧបត្ថម សមាគមន៍ Asia Creation**

**កាលវិភាគ** ខែ៧ ថ្ងៃទី២៨ (អាទិត្យ) Nogoya
ខែ៨ ថ្ងៃទី៤ (អាទិត្យ) Tokyo

*ព័ត៌មានលម្អិតដូចបានកំណត់តាមកាលវិភាគខាងលើ

## ខែ៥ក្នុងថ្ងៃឈប់សម្រាកពិតជាបានសប្បាយណាស់ ។




នៅផ្ទះឪពុកម្តាយរបស់ថៅកែបានទៅជីកទំពាំងនិងអាំងសាច់ ។

យើងបានទៅ Shirakawagou ជាកន្លែងបេតិកភណ្ឌពិភពលោក ជាមួយនិងគ្រួសារថៅកែ




## ចាប់ពីឥឡូវ រឿងដែលអាចធ្វើបានចំពោះអ្នកដែលត្រូវប្រលងតេស្តសមត្ថភាព ភាសាជប៉ុននៅខែ៧



ម៉ាសាកុ ហុរិកុសុិ(គ្រូបង្រៀនភាសាជប៉ុន)

### រឿងដែលត្រូវធ្វើទុក១ខែមុន

នៅពេលដល់រយៈពេល១ខែមុនពេលប្រលង មិនត្រូវធ្វើលំហាត់ថ្មី ឬកម្មវិធីថ្មីជាដើម។ មានមនុស្សជាច្រើន នៅពេលដែលចាប់ផ្តើមលំហាត់ថ្មី និងមានកន្លែងដែលយើងមិនចេះធ្វើជាច្រើនចេញមក ស្លន់ស្លោ ហើយថែមទាំងធ្វើអោយយើងបាត់បង់ទំនុកចិត្ត លើខ្លួនឯងទៀតផង ។ រំលឹកនូវមេរៀនដែលបានរៀនរួចបញ្ជាក់កន្លែងដែលមិនច្បាស់លាស់ឡើងវិញ ដើម្បីបង្កើនទំនុកចិត្ត ។

### រឿងដែលត្រូវធ្វើមុនថ្ងៃប្រឡង

សូមកុំផឹកស្រា ហើយចូលគេងអោយបានឆាប់ជាងរាល់ដង ។ ប្រសិនបើផឹកស្រានិងធ្វើអោយយើងងងុយគេង ។ អ្នកដែលចង់ផឹកស្រា ចាំប្រលងចប់សិន ។

### រឿងដែលត្រូវធ្វើនៅថ្ងៃប្រលង

កំហុសភាគច្រើនដែលតែងតែកើតមាននៅថ្ងៃប្រលង មានដូចជា ដោយសារតែមិនស្គាល់កន្លែងប្រលងហើយទៅយឺត មិនអាចចូលប្រលងបាន និងនៅងងុយដេកនៅពេលប្រលងអំពីការស្តាប់ជាដើម ។ សូមកុំដេករហូតគៀកម៉ោងប្រលង ។ ត្រូវក្រោកពីគេង ហើយញ៉ាំបាយ រួចហើយពិនិត្យមើល ថាតើមានភ្លេចរបស់អ្វីអត់មុននិងចេញទៅប្រលង ។ ការប្រលងគឺនៅពេលរសៀល ត្រូវប្រុងប្រយ័ត្នចំពោះម៉ោងបាយថ្ងៃត្រង់ ហើយមិនត្រូវអោយងងុយគេងនៅម៉ោងប្រលងស្តាប់ ។ ហើយបន្ទាប់មក ត្រូវខំប្រឹងធ្វើអោយមានទំនុកចិត្តលើខ្លួនឯង ។